ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១០ អយក.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និង កែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា។ ក្រុមការងារបច្ចេកទេសនេះ ស្ថិតក្រោមឱវាទគណៈកម្មការពិនិត្យឡើងវិញកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ៣៥០៨ អយក.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ៤២៧ ៣៩៦ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា មានសមាសភាពដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១. | លោកជំទាវ | **គឹម** | **សេដ្ឋានី** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | លោកជំទាវ | **ឃុន** | **រចនា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម | **សំ** | **សេរីរតន៍** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៤. | លោក | **ឡោ** | **ឆវណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៥. | លោក | **ប្រាក់** | **កុសល** | ប្រធាននាយកដ្ឋានអប់រំកុមារតូច | សមាជិក |
| ៦. | លោកស្រី | **ផ្លុង** | **មុនីកុសល** | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច | សមាជិក |
| ៧. | លោកស្រី | **អ៊ុក** | **សុមនី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| ៨. | លោក | **ឈួន** | **ម៉ិនឈឿន** | ប្រធានការិយាល័យ នា. អប់រំកុមារតូច | សមាជិក |
| ៩. | លោកស្រី | **អ៊ុម** | **សុផានី** | ប្រធានការិយាល័យ នា. អប់រំកុមារតូច | សមាជិក |
| ១០. | លោកស្រី | **រស់** | **សេដ្ឋា** | ប្រធានការិយាល័យ នា. អប់រំកុមារតូច | សមាជិក |
| ១១. | លោក | **មួង** | **ចាន់ឆួច** | ប្រធានការិយាល័យ នា. ប.វ | សមាជិក |
| ១២. | កញ្ញា | **ម៉ៅ** | **ណារី** | ប្រធានការិយាល័យ នា. ប.វ | សមាជិក |
| ១៣. | លោកស្រី | **មៀច** | **ច័ន្ទស៊ីថា** | អនុប្រធានការិយាល័យ នា. អប់រំកុមារតូច | សមាជិក |
| ១៤. | លោក | **ឆន** | **ឈាង** | អនុប្រធានការិយាល័យ នា. អប់រំកុមារតូច | សមាជិក |
| ១៥. | លោក | **លឹម** | **សិរីវុឌ្ឍី** | អនុប្រធានការិយាល័យ នា. នីតិកម្ម | សមាជិក |
| ១៦. | លោកស្រី | **ខ៊ុយ** | **គឹមច័ន្ទដារ៉ា** | នាយិការរង ស.គ.ម.ម | សមាជិក |
| ១៧. | លោកស្រី | **សេង** | **សុខវណ្ណា** | ប្រធានការិយាល័យសិក្សា ស.គ.ម.ម | សមាជិក |
| ១៨. | លោកស្រី | **កែ** | **រ៉ា** | អនុប្រធានការិយាល័យសិក្សា ស.គ.ម.ម | សមាជិក |
| ១៩. | លោកស្រី | **ថន** | **ទ៉ាន់ថា** | អនុប្រធានក្រុមបច្ចេកទេស ស.គ.ម.ម | សមាជិក |
| ២០. | លោកស្រី | **សំច័ន្ទ** | **រស្មី** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| ២១. | លោក | **អ៊ូ** | **សារឿន** | មន្ត្រីនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ២២. | **តំណាងអង្គការ** | | | UNICEF | សមាជិក |

**ប្រការ ៣.-**

ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា មានភារកិច្ច៖

- ដឹកនាំនិងសម្របសម្រួលការងារកម្រិតថ្នាក់ជាតិលើសកម្មភាពអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា
- គាំទ្រនិងលើកទឹកចិត្តលើការងារកសាងគោលការណ៍និងឯកសារនានា។

**ប្រការ ៤.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋាននីតិកម្ម នាយិកាសាលាគរុកោសល្យមត្តេយ្យមជ្ឈិម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ៧ ឆ្នាំ២០១៤

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យក្រសួង អ.យ.ក.
- អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ នា. នីតិកម្ម